# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ :** ១៥៤/២៤ **ក.ប/ស.ណ.ន.វ.ក**

# សេចក្តីណែនាំ
## ស្តីពី
## ការផ្សះផ្សាវិវាទការងារសាឡើងវិញ

កន្លងមក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសង្កេតឃើញថា ការផ្សះផ្សាវិវាទការងារមិនទាន់អាចឆ្លើយតបបានតាមតម្រូវការរបស់ភាគីវិវាទ ដែលធ្វើឱ្យអត្រាសះជាមិនទាន់សម្រេចបាន ១០០% នៅឡើយ។

ដើម្បីពង្រឹងប្រសិទ្ធភាពនៃការផ្សះផ្សាវិវាទការងារ និងឆ្លើយតបតាមសំណូមពររបស់ភាគីវិវាទ ដែលជានិយោជកនិងកម្មករនិយោជិត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមដាក់ចេញនូវគោលការណ៍ណែនាំស្តីពីនីតិវិធីនៃការផ្សះផ្សាវិវាទការងារសាឡើងវិញ ដូចខាងក្រោម៖

១. ក្នុងរយៈពេល ២ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីការផ្សះផ្សាវិវាទការងារដោយអធិការការងារ ឬអ្នកផ្សះផ្សាដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនទទួលបានលទ្ធផលសះជា ភាគីវិវាទអាចស្នើសុំជាលាយលក្ខណ៍អក្សររួមគ្នាមករដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើការផ្សះផ្សាវិវាទការងារសាឡើងវិញ។

២. រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចចាត់តាំង ឬប្តូរអ្នកផ្សះផ្សាដើម្បីធ្វើការផ្សះផ្សាវិវាទការងារនេះសាឡើងវិញបានស្របតាមនីតិវិធី ដែលមានចែងក្នុងច្បាប់ស្តីពីការងារ។

៣. ប្រសិនបើការផ្សះផ្សាវិវាទការងារសាឡើងវិញនេះមិនទទួលបានលទ្ធផលសះជា ភាគីវិវាទមិនអាចស្នើសុំឱ្យធ្វើការផ្សះផ្សាសាឡើងវិញជាថ្មីម្តងទៀតបានទេ។ ភាគីវិវាទត្រូវគោរពតាមនីតិវិធីបន្តសម្រាប់ការដោះស្រាយវិវាទការងារនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន តំណាងនិយោជក អង្គការវិជ្ជាជីវៈរបស់និយោជក កម្មករនិយោជិត តំណាងកម្មករនិយោជិត និងអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃសុក្រ ១កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ